## ៣-១ នមស្សការ ថ្វាយបង្គំព្រះពុទ្ធ

**-ឥតិបិ សោ ភគវា** ព្រះមានព្រះភាគអង្គនោះ មាន គុណ ១០ប្រការ ដូចនេះ :

**១-អរហំ** ព្រះអង្គឆ្ងាយចាកសិកសត្រូវពោលគឺ កិលេសព្រមទាំងវាសនា គឺកាយបយោគនិងវចីបយោគ,

**២-សម្មាសម្ពុទ្ធោ** ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គ ឡើយ,

**៣-វិជ្ជាចរណសម្បន្នោ** ព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ និងវិជ្ជា៨ និងចរណ១៥,

**៤-សុគតោ** ព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរដ្ឋាន គឺអមតមហានិព្វាន,

**៥-លោកវិទូ** ព្រះអង្គជ្រាបច្បាស់នូវត្រៃ លោក,

**៦-អនុត្តរោ** ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន,

**៧-បុរិសទម្មសារថិ** ព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មាន បាន,

**៨-សត្ថា ទេវមនុស្សានំ** ព្រះអង្គ ជាសាស្តាចារ្យ នៃទេវតា និងមនុស្សទាំងឡាយ,

**៩-ពុទ្ធោ** ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង,

**១០-ភគវា** ព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

**-តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវ

*ព្រះ សម្មាសម្ពុទ្ធ ជាម្ចាស់ ព្រះអង្គ ប្រកបព្រមហើយដោយគុណមាន គុណថាអរហំ ជាដើមនោះ ដោយ សិរសា គឺត្បូង,*

**-តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណាសូមបូជាចំពោះ នូវព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គនោះ ដោយគ្រឿងសក្ការទាំងឡាយមាន ប្រមាណប៉ុណ្ណោះ ។*

*(ក្រាបថ្វាយបង្គំម្តង)*

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*